# ហោអដ្ឋិធាតុ

# THE URN LIBRARY

វត្តលង្កា ព្រះកុសុមារាម, ក្រុងភ្នំពេញ



WAT LANGKA (PAGODA), PHNOM PENH

DOCUMENTATION CENTER OF CAMBODIA

23 DECEMBER 2023



# ហោអដ្ឋិធាតុ

## វត្តលង្កា ព្រះកុសុមារាម, ក្រុងភ្នំពេញ





ឈ្មោះអ្នកឧបត្ថម កាលបរិច្ឆេទ នៅក្នុងវិមានអណ្តែតទ្រដោយសត្វហង្ស តំណាងឲ្យសត្វពិសិដ្ឋទ្រសំណង់ព្រះអាទិទេព។ វិមានអណ្តែតនេះជាគំនិតដែលបានទាញចេញពីចម្លាក់វិមានអណ្តែតតាមប្រាសាទបុរាណខ្មែរនា ស.វ.ទី៧ នៅតំបន់ឥសានបុរៈ ក្នុងខេត្តកំពង់ធំ។





Youk Chhang and Sun Pora

ហោអដ្ឋិធាតុ នៃវត្តលង្កា ក្រុងភ្នំពេញ ត្រូវបានរចនាឡើងដោយគិតគូរពីបរិយាកាសនៃប្រទេសកម្ពុជា។ ក្រៅអំពីរចនាសម្រួបតាមមុខងារនៃអគារ ការរចនាក៏បានផ្តោតខ្លាំងពីសុវត្ថិភាព ខ្យល់ និងពន្លឺ។ បង្អួចទាំងអស់ត្រូវបានបំពាក់ដោយចម្រឹងដែក និងកញ្ចក់។ កញ្ចក់នៃទិសខាងជើង និងខាងកើត ជាប្រភេទ **awning window** ដែលធ្វើឲ្យបន្ទប់មានខ្យល់ចេញចូល បន្ទប់មិនក្តៅ និងមិនធ្វើឲ្យជាតុមិនឆាប់ពុកផុយ។ ដោយឡែក ផ្ទៃខាងក្នុងត្រូវបានតុបតែងលម្អតាមបែបផែនខ្មែរនិយមពីបុរាណកាល។ ក្នុងការរចនា យើងព្យាយាមធ្វើយ៉ាងណាឲ្យទីនេះសាកសមជាទីសក្ការៈបូជា ជាកន្លែងសិក្សាស្វែងយល់ និងពុំមានការភ័យខ្លាច។ លើផ្ទៃជញ្ជាំងទាំងឡាយនៃអគារត្រូវបានលម្អយ៉ាងពិចិត្រដោយតួអង្គទេព្តា កិន្នរ ទេពនិករផ្សេងៗ កំពុងបាចផ្កា ហាក់ឧទ្ទិសកុសលដល់អ្នកដែលបានចែកឋានទៅ ដែលមើលទៅប្រៀបបានទៅនឹងទីស្ថានសួគ៌។ ទាំងនេះជាគំនូរបុក ដែលខ្មែរនិយមនាដើមឆ្នាំ១៩០០ នៅតាមទីវត្តអារាមនានាក្នុងព្រះរាជាណាចក្រ។ ក្នុងការដំណើរការជាដំបូង គេរំលីងផ្ទៃដែលនឹងត្រូវគូរនោះឲ្យស្មើល្អ រួចហើយទើបយកថ្នាំពណ៌លាបលនឲ្យបានជាផ្ទៃរលោងស្រិល។ គេគូររូបរាងក្បាច់ ឬតួអង្គអ្វីមួយដែលចង់បាននោះលើក្រដាសសិន រួចហើយទើបគេកាត់ចោះទម្លុះតាមរាងរៅដែលចង់បានធ្វើជាពុម្ព។ បន្ទាប់មកទើបគេយកពុម្ពនោះទៅបិទភ្ជាប់លើទីដែលត្រូវមានរូប ដោយប្រើជក់លាបថ្នាំពណ៌មាស ទៅលាបថើៗតាមរន្ធពុម្ពជារាងក្បាច់ដែលបានកាត់។ បានដូច្នោះហើយ ទើបគេបកពុម្ពក្រដាសចេញ។ ចំណែកឯ ពាក្យថា "បុក" នោះគឺតាមពិតគ្រាន់តែយកទៅប្រថាប់ថ្នមៗលើរន្ធពុម្ពប៉ុណ្ណោះ។ នៅតាមធ្នឹម ក៏មានលម្អក្បាច់រំយោលផ្កាព័ទ្ធជុំវិញផងដែរ។ នៅជញ្ជាំងខាងលិច មានចារឹកពីឈ្មោះអ្នកឧបត្ថម កាលបរិច្ឆេទ នៅក្នុងវិមានអណ្តែត ទ្រដោយសត្វហង្ស តំណាងឲ្យសត្វពិសិដ្ឋទ្រសំណង់ព្រះអាទិទេព។ វិមានអណ្តែតនេះជាគំនិតដែលបានទាញចេញពីចម្លាក់វិមានអណ្តែតតាមប្រាសាទបុរាណខ្មែរនា ស.វ.ទី៧ នៅតំបន់ឥសានបុរៈ ក្នុងខេត្តកំពង់ធំ។ នៅចំបង្អួចមានអសនៈ៥ថ្នាក់ មានតំកល់ព្រះពុទ្ធរូបក្នុងកាយវិការសម្តែងធម៌ធម្មចក្រ ជាឥរិយាបថដែលព្រះអង្គសម្តែងធម៌ដំបូងបង្អស់ (គឺធម៌ធម្មចក្រ) ដល់ភិក្ខុទាំង៥អង្គ បែរទៅទិសខាងកើត។

*ស៊ុន ពោរ៉*

# THE URN LIBRARY

## INSPIRED BY THE CONCEPT OF A STUPA BEING BLESSED FROM HEAVEN

By Sun Pora

The Urn Library, located at Wat Langka in Phnom Penh, is meticul reflect the unique ambiance of Cambodia. In addition to its functional aspects, the design of the library also places significant emphasis on safety, optimal air circulation, and ample natural lighting. All windows are elegantly adorned with steel bars and glasses. On the north and east sides, the library is equipped with awning windows, strategically designed to ensure sufficient air circulation, and maintain moderate temperatures within the room, thereby effectively preventing the rapid decay of the urns. Furthermore, the interior of the room has been thoroughly ornamented with traditional Khmer decorative patterns, adding an authentic touch to the overall aesthetic. Throughout the design process, our utmost priority was to create a space that serves as a respectful sacred site while also promoting a conducive learning environment, while simultaneously creating an atmosphere that lessens any potential anxiety or fear among visitors. Embellishing each wall surface are exquisite printed artworks portraying gods, goddesses (i.e. Kenors), and other mythical characters elegantly showering flowers as a solemn tribute to the deceased. Collectively, these elements create a celestial setting, evoking a heavenly vista. These captivating artworks are commonly referred to as "Boke" style paintings, a renowned form of Khmer art that gained popularity during the early 1900s. They were commonly used as the decorative elements of pagodas across Cambodia during that period. In the creation of a "Boke" style painting, the initial step is to ensure a smooth and even wall surface. Following this, an additional layer of paint is applied to create a smooth and seamless finish. Subsequently, the artists proceed to sketch the desired shape of the "Kbach" (ornament) or character on a sheet of paper. They then carefully cut out this shape, creating a template to be used as a mold. Next, the artist affixes the mold onto the wall and delicately applies golden paint to the shape using a paintbrush, carefully following the outline provided by the mold. Lastly, the artist carefully removes the mold from the wall, completing the process. In this context, "Boke" refers to the technique of applying paint lightly, following the outline provided by the mold. Flowery artworks are utilized as ornamental decorations on each lintel of the library. A floating monument painting, fixed onto the west wall, is positioned on top of phoenixes; within the monument, a list of donors and dates is inscribed. The phoenix, a mythological creature, serves as the foundational support for this celestial monument. The concept of the floating monument, which has been incorporated into the design, draws inspiration from traditional Khmer temples dating back to the 7th century. These temples are located in the Isanapura area of Kampong Thom province. In front of the window, there is a five-layered seat holds a Buddha statue positioned on top. The Buddha statue is depicted in the Bhumisparsha Mudra, also known as the Earth Touching Gesture. This significant gesture symbolizes the Buddha, facing eastward, imparting the Thamajak Dharma, representing the foundational teachings, to a group of five Buddhisht monks.

# ហោអដ្ឋិធាតុ

ការតស៊ូឥតឈប់ឈរ ក្នុងការឆ្លើយតបចំពោះអំពើប្រល័យពូជសាសន៍លើវប្បធម៌ ដែលបានកើតមានពីអតីតកាល ព្រមទាំងបានបន្តរហូតមកដល់សព្វថ្ងៃ

ដោយ **ឆាំង យុ**

ប្រវត្តិសាវតារនៃហោអដ្ឋិធាតុ ឬបណ្ណាល័យអដ្ឋិធាតុ ផ្សារភ្ជាប់ទំនាក់ទំនងស៊ីជម្រៅជាមួយនឹងប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសកម្ពុជា ក៏ដូចជា ការតស៊ូរបស់ប្រជាជនកម្ពុជា ក្នុងការជាសះស្បើយពីអតីតកាលរបស់ខ្លួន

នៅក្នុងឆ្នាំ ២០១៥ បងស្រីរបស់ខ្ញុំឈ្មោះ កែវ កុលធីតា ឯកស័ក បានទទួលមរណភាព ក្រោយពីបានព្យាយាមជម្នះនឹងជំងឺមហារីកអស់រយៈពេលជាច្រើនឆ្នាំ។ បងស្រីរបស់ខ្ញុំ គឺជាមនុស្សគថ្លង់ពីកំណើត។ គាត់ជាកូនស្រីពៅគេបង្អស់ក្នុងចំណោមបងស្រីប្រាំនាក់របស់ខ្ញុំ។ គាត់មានអាយុខុសគ្នាជាមួយខ្ញុំត្រឹមតែពីរឆ្នាំប៉ុណ្ណោះ ហេតុដូច្នេះ គាត់និងខ្ញុំហាក់បីដូចជាមិត្តជិតស្និទ្ធនឹងគ្នា។ មរណភាពរបស់គាត់ គឺជាពេលវេលាដ៏លំបាកលំបិនមួយសម្រាប់ខ្ញុំ ហើយខ្ញុំបានបួសជាសង្ឃនៅវត្តលង្កា ក្រោយការលាចាកលោកទៅរបស់គាត់។ ក្រោយពីមរណភាពរបស់គាត់ ព្រះសង្ឃបានលើកទឹកចិត្តឲ្យខ្ញុំតាំងសម្មាធិ ហើយខ្ញុំក៏បានដើរចង្ក្រមជុំវិញបរិវេណព្រះវិហារ។ នៅពេលដែលខ្ញុំដើរចង្ក្រមជុំវិញបរិវេណព្រះវិហារ, ដោយចៃដន្យ, ខ្ញុំបានសង្កេតឃើញពន្លឺលេចចេញពីប្រឡោះតូចមួយនៅក្បែរធេញ្ណូរង្សីនៃព្រះពុទ្ធប្បដិមា។ ខ្ញុំបានស្នើសុំព្រះសង្ឃនៅក្នុងវត្ត ឲ្យជួយរំកិលព្រះពុទ្ធប្បដិមា ដើម្បីដឹងថា តើពន្លឺលេចឡើងនោះ មានប្រភពមកពីណា។ ព្រះសង្ឃប្រមាណជាង ១៥ អង្គរួមគ្នា ទើបអាចរំកិលព្រះពុទ្ធប្បដិមាធ្វើឡើងពីស៊ីម៉ង់ត៍មួយអង្គនេះរួច។ ក្រោយពីរំកិលពុទ្ធប្បដិមា យើងបានប្រទះឃើញរូងបង្កប់មួយនៅពីក្រោយទ្វារមួយផ្ទាំងដែលជាប់សោរ និងច្រវាក់។ រូងនៅពីក្រោយទ្វារជាប់សោរ និងច្រវាក់នោះ មានសណ្ឋានងងឹត និងគួរឲ្យព្រឺក្បាល។ ទោះបីជាយ៉ាងនេះក្តី យើងបានសម្រេចចិត្តបើកទ្វារនោះដើម្បីពិនិត្យថាតើមានអ្វីនៅពីក្រោយ។ នៅពេលដែលយើងបើកទ្វារដោយប្រើពិលដើម្បីឆ្លុះមើល យើងបានឃើញកោដ្ឋដែលត្រូវបានទុកជាគំនរៗ រុំព័ទ្ធជុំជិតទៅដោយធូលី និងសំបុកពីងពាងជាច្រើន។



A Khmer Rouge Survivor:
Keo Sokhal Reatrey.

គណៈកម្មការវត្តលង្កា បានអនុញ្ញាតឲ្យខ្ញុំរើយកកោដ្ឋទាំងអស់ចេញពីក្នុងរូងនោះ រួចចាត់ថ្នាក់និងថតរូបទុកជាឯកសារ។ យើងកំណត់បានថា មានកោដ្ឋសរុបចំនួន ៤៦៤។ ដោយសារតែមកទល់សព្វថ្ងៃ គណៈកម្មការវត្តលង្កា នៅតែពុំទាន់រកឃើញកោដ្ឋតម្កល់អដ្ឋិធាតុ**សម្តេចព្រះធម្មលិខិត ល្វី ឯម** នៅឡើយ មានការសន្មតថា អដ្ឋិធាតុរបស់ព្រះតេជគុណ អាចស្ថិតនៅក្នុងចំណោមកោដ្ឋចំនួនរាប់រយនេះ។ ព្រះញាណបវរវិជ្ជា ល្វី ឯម (វជិរប្បញ្ញោ) បានទទួលងារជាព្រះចៅអធិការនៃវត្តលង្កា នៅក្នុងឆ្នាំ១៩១២។ ក្រោយមកព្រះអង្គ ត្រូវបានគោរពទទួលស្គាល់អំពីស្នាព្រះហស្តដ៏ថ្លៃថ្លាក្នុងការសម្រេចបានការសាងសង់ទីអារាមជាទីសក្ការៈនេះ។



A visitor: Eng Sokmeng



កោដ្ឋភាគច្រើន មានសភាពបាក់បែក ធ្វើឲ្យយើងមិនអាចកំណត់អំពីព័ត៌មានដែលសរសេរបិទភ្ជាប់ទៅនឹងកោដ្ឋទាំងនោះបាន កុំថាឡើយកំណត់ពីអាយុនៃកោដ្ឋទាំងនោះ។ កោដ្ឋខ្លះមានកាលបរិច្ឆេទបិទភ្ជាប់ ដែលយើងអាចសន្មតថាកោដ្ឋទាំងនេះ ត្រូវបានបន្សល់ពីជំនាន់សង្គ្រាមស៊ីវិល ដែលកើតមានឡើងក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ចំណែកឯកោដ្ឋខ្លះត្រូវបានបន្សល់ទុកពីដើមទសវត្សរ៍ឆ្នាំ១៩៩០។ ទោះបីជាយ៉ាងណាក្តី ឆ្លងកាត់ការសិក្សាស្រាវជ្រាវរបស់យើង យើងជឿជាក់ថា ភាគច្រើននៃកោដ្ឋទាំងនេះ ត្រូវបានបោះបង់ចោលនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥។

ភ្លាមៗបន្ទាប់ពីខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហម បានបង្ខិតបង្ខំប្រជាជនក្នុងទីក្រុងភ្នំពេញទាំងអស់ឲ្យចាកចេញ និងធ្វើការនៅក្នុងសហករណ៍ដែលខ្មែរក្រហមបានបង្កើតឡើងនៅទីជនបទ។ ប្រជាជន ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ដោយនាំយកទៅជាមួយនូវរបស់របរបន្តិចបន្តួច ដែលខ្លួនអាចកាន់យកទៅជាមួយបាន។ ប្រជាជនខ្លះ បាននាំយកអដ្ឋិធាតុសាច់សាលោហិតរបស់ខ្លួន ទៅផ្ញើទុកនៅឯ វត្តលង្កា ដោយប្រហែលជារំពឹងថា ខ្លួនអាចសុំយកអដ្ឋិធាតុទាំងនោះត្រលប់មកវិញនៅពេលដែលខ្លួនវិលមកកាន់ទីក្រុងភ្នំពេញ ក្រោយពេលប្រទេសមានសន្តិភាព។

ព្រះសង្ឃ ដែលទទួលរក្សាទុកកោដ្ឋទាំងនេះ កាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ បានទទួលអនិច្ចធម្ម។ ក្រោយពីព្រះតេជគុណអង្គនោះ ទទួលអនិច្ចធម្មទៅ ព័ត៌មានស្តីអំពីរូងតម្កល់កោដ្ឋនេះ ក៏បានសាបសូន្យទៅតាមព្រះអង្គ ពីព្រោះថាពុំមានព្រះសង្ឃមួយអង្គណានៅក្នុងវត្តលង្កា បានដឹងអំពីរូងសម្ងាត់នេះឡើយ នៅមុនពេលត្រូវបានពើបប្រទះឃើញសាជាថ្មី នៅក្នុងឆ្នាំ២០១៥។

ដោយមានការគាំទ្រយ៉ាងសប្បុរសពីសំណាក់ស្ថានទូតអាមេរិក, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងទាហានជើងទឹកសហរដ្ឋអាមេរិកប្រចាំនៅប្រទេសជប៉ុន យើងបានសាងសង់ទូឈើ សម្រាប់តម្កល់កោដ្ឋទាំងអស់នេះ។ បច្ចុប្បន្ន កោដ្ឋទាំងនេះ ត្រូវបានតម្កល់រក្សាទុកនៅក្នុងទូឈើទាំង ១០ នៅវត្តលង្កា។ ចាប់តាំងពីពេលដែលយើង

បានស្រាវជ្រាវរកឃើញកោដ្ឋទាំងនេះ និងបានតម្កល់ទុកនៅទីតាំងសមរម្យជាងមុន នៅវត្តលង្កា យើងបានធ្វើសេចក្ដីប្រកាសអំពីវត្តមាននៃកោដ្ឋទាំងនេះ ដោយសង្ឃឹមថា ក្រុមគ្រួសារនៃកោដ្ឋ អាចមកទទួលយកត្រឡប់ទៅវិញ។ តាមលំអាននៃទំនៀមទម្លាប់ខ្មែរស្របនឹងព្រះពុទ្ធសាសនា, កោដ្ឋទាំងអស់នេះ, ពុំអាចត្រូវបោះបង់ចោលទេ។ កោដ្ឋទាំងនេះត្រូវទទួលបានសេចក្ដីគោរពឲ្យបានសមស្របតាមប្រពៃណី។ ទោះបីជាយ៉ាងណាក្ដី អស់រយៈពេលជាង៨ឆ្នាំ បន្ទាប់ពីការរកឃើញកោដ្ឋទាំងនេះ មានតែក្រុមគ្រួសារចំនួន៩ តែប៉ុណ្ណោះដែលបានដឹង និងខ្លះបានមកទទួលយកអដ្ឋិធាតុនៃសាច់សាលោហិតរបស់ខ្លួនត្រឡប់ទៅវិញ។ យើងជឿជាក់ថា ចំពោះកោដ្ឋដែលបានរក្សាទុកនៅក្នុងអំឡុងពេលនៃការជម្លៀសចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសារនៃអដ្ឋិធាតុ ដែលបានយកកោដ្ឋមកតម្កល់ទុកនៅក្នុងអំឡុងពេលនៃការជម្លៀសកាលពីឆ្នាំ១៩៧៥នោះ អាចបាត់បង់ជីវិតទៅអស់ហើយ ទើបពុំអាចមកទទួលយកកោដ្ឋទាំងនេះត្រឡប់ទៅវិញ។

ឆ្លងកាត់ការពិភាក្សារវាងព្រះចៅអធិការវត្តលង្កា សម្ដេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទថុល្ល និងគណៈកម្មការគ្រប់គ្រងវត្តលង្កា ព្រះតេជគុណ បានសម្រេចប្រទានបន្ទប់មួយចំនួននៅអគារកំពុងសាងសង់ថ្មី ក្នុងបរិវេណវត្តលង្កា ដើម្បីតម្កល់កោដ្ឋទាំងនេះព្រមទាំងធ្វើជាបណ្ណាល័យនិងទីតាំងសម្រាប់ភ្ញៀវក្នុងការសិក្សារៀនសូត្រ, សម្មាធិ និងឈ្វេងយល់អំពីប្រវត្តិសាស្ត្រ, វប្បធម៌ និងអត្ថន័យផ្នែកសាសនា របស់កោដ្ឋទាំងនេះ នៅក្នុងបរិបទនៃអត្តសញ្ញាណរបស់កម្ពុជា, ទំនៀមទម្លាប់ក្នុងព្រះពុទ្ធសាសនា និងមនុស្សជាតិ។ សម្ដេចព្រះចៅអធិការ ក៏បានប្រទាននូវបន្ទប់តូចចំនួន២ ទុកសម្រាប់ភ្ញៀវស្នាក់នៅ ព្រមទាំងបន្ទប់មួយទៀតសម្រាប់ថ្វាយបង្គំព្រះពុទ្ធជាម្ចាស់។ ខ្លឹមសាររៀបរាប់ខាងលើ គឺជាប្រវត្តិសាវតារនៃ«ហោអដ្ឋិធាតុ ឬ បណ្ណាល័យអដ្ឋិធាតុ» នៅក្នុងវត្តលង្កាដែលជាទីតម្កល់កោដ្ឋ និងជាបណ្ណាល័យតម្កល់សៀវភៅ អមជាមួយនឹងឯកសារប្រវត្តិសាស្ត្រ និងសាសនា។

ការអភិរក្ស និងការការពារកោដ្ឋទាំងអស់នេះ គឺស្របទៅតាមចក្ខុវិស័យរបស់លោក រ៉ាហ្វាអែល លេមឃីន តាំងពីឆ្នាំ១៩៤៤ មកម្ល៉េះ ក្នុងការរារាំងទប់ស្កាត់ និងផ្ដន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ នៅមុនពេលដែលយើងសម្រេចកំណត់បាននូវនិយមន័យផ្លូវច្បាប់នៃឧក្រិដ្ឋប្រល័យពូជសាសន៍ដូចសព្វថ្ងៃ លោក លេមឃីន បានកំណត់ថា ការបំផ្លិចបំផ្លាញលើវត្ថុ និងបេតិកភណ្ឌវប្បធម៌ គឺជាទង្វើមួយដែលចាត់ចូលជាអំពើប្រល័យពូជសាសន៍លើវប្បធម៌។ កិច្ចការដែលបម្រើដល់ការកំណត់អត្តសញ្ញាណ, ការគោរព និងការអភិរក្សកោដ្ឋទាំងអស់ ដែលស្ទើរតែបាត់បង់ទៅដោយសារតែរបបខ្មែរក្រហមបង្កឡើងកាលពី៥០ឆ្នាំមុន ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាកិច្ចការបំពេញបន្ថែមចំពោះការតស៊ូឥតឈប់ឈរ ក្នុងការឆ្លើយតបចំពោះអំពើប្រល័យពូជសាសន៍លើវប្បធម៌ ដែលបានកើតមានពីអតីតកាល ព្រមទាំងបានបន្តរហូតមកដល់សព្វថ្ងៃ។






Youk Chhang and Visitors



Long Dany and Ly Sok-Kheang

# THE URN LIBRARY

## THE ONGOING STRUGGLE TO RESPOND TO CULTURAL GENOCIDE OF THE PAST, AND WHICH CONTINUES TODAY

By **YOUK CHHANG**

**The history of the Urn Library is deeply connected to the modern history of Cambodia and Cambodians' struggle to reclaim their past**

In 2015, my sister, Keo Kolthida Ekkasakh, passed away after a long struggle with cancer. She was born deaf as the youngest of five sisters, two years apart from me, and we were best friends throughout life. Her death was extremely difficult for me, and I committed to becoming a monk at Wat Langka (pagoda) after she died. In the wake of her death, the monks encouraged me to meditate by walking around the pagoda. I walked around Preah Vihear of Wat Langka and by accident I noticed a light coming from near the lamp of the Buddha statue. I was able to convince the monks to move the statue to see where the light was coming from. It took 15 people to move the cement Buddha aside and they found a hidden cave that was locked behind a large gate. The gateway looked very dark and spooky, but we decided to open the gate to find out what was behind it. When we opened it, we found piles and piles of urns that were covered in cobwebs, dust, and spiders.

Wat Langka gave me permission to remove the urns to catalogue and photograph them and we identified 464 urns. Because Wat Langka has yet to find the remains of Venerable Preah Nhanapavaravichea Louis Em (Vajirappanno), it is believed that his remains may actually be among these several hundred urns. The Venerable Preah Nhanapavaravichea Louis Em (Vajirappanno) was the first head of the pagoda in 1912, and he is attributed with the extraordinary honor of having completed the building of this sacred pagoda.

Most urns had degraded to such a degree that it was impossible to identify the writing on them, let alone determine their age. Some urns are dated, and we can say that they were left during Cambodia's civil war in the 1980s and a few from the early 1990s. However, we came to learn, and it is our belief that, many of these urns were abandoned during the evacuation of Phnom Penh in 1975.

Shortly after the Khmer Rouge entered Phnom Penh in April 1975, they forced the entire population to leave the city to live and work in cooperatives. People were forced to leave the city with only the items they could carry, and







Venerable Samdech Preah Dhammaliket Dr. Sao Chanthol, The Chief Abbot of Langka Pagoda Preah Kossomaram





some people brought their family's remains to Wat Langka for safe keeping presumably with the expectation that they could claim the urns when they returned to Phnom Penh.

The monk who accepted these urns from the 1970s has since died and, apparently when he died, the knowledge of this hidden cave passed with him because no one at Wat Langka was aware of this secret cave until it was rediscovered in 2015.

With the generous assistance from the U.S. Embassy, the U.S. Agency for International Development, and the U.S. Navy Seabees in Japan, we had ten wooden cabinets built for the urns and the urns are currently secured in these cabinets in Wat Langka today. Since discovering the urns and putting them into a more respectful place in Wat Langka, we have made announcements about the existence of these urns with the hope that families would come forward to claim them. According to Buddhist tradition, these urns cannot be abandoned, and

they have to be treated respectfully. However, it has been almost 8 years since our discovery of these urns and only 9 families have come forward to claim them. We believe that at least for those urns left during the evacuation of Phnom Penh, there are no family members alive who were present during the evacuation of 1975 to reclaim these urns.

After further discussion with the Head of the Wat Langka (pagoda), Samdech Preah Thammalikhet Dr. Sao Chanthol, and his pagoda committee, they decided to dedicate an entire set of rooms in Wat Langka to not only hold these urns but also serve as a library and a place for visitors to learn, meditate, and reflect upon the history, culture, and spiritual meaning of the urns in the context of Cambodia's identity, Buddhist tradition, and humanity in general. Wat Langka has even set aside 2 small rooms for guests to stay overnight and another room for praying. This is the story of 'The Urn Library' at Wat Langka, which houses the urns, a history book about the library, and other historical and religious texts.

In many ways, preserving and protecting these urns is an extension of fulfilling Raphael Lemkin's vision since 1944 of preventing and punishing the crime of genocide. Before we arrived at our current legal definition of the crime of genocide, Lemkin identified the destruction of cultural artifacts and heritage as a kind of cultural genocide. The work in reclaiming, respecting, and protecting these urns, which were nearly lost to the Khmer Rouge regime almost 50 years ago in the evacuation of Phnom Penh, is a work in furtherance of the ongoing struggle to respond to cultural genocide of the past and which continues to plague Cambodia and humanity today.

— *Khmer Times*



Yin Nean & Ly David

# CAMBODGE : L'HISTOIRE OUBLIÉE DE LA BIBLIOTHÈQUE DES URNES DU WAT LANGKA

By **YOUK CHHANG**

## L'histoire de la bibliothèque des urnes est profondément liée à l'histoire moderne du Cambodge et à la lutte des Cambodgiens pour se réapproprier leur passé

En 2015, ma sœur, Keo Kolthida Ekkasakh, est décédée après une longue lutte contre le cancer. Elle était née sourde et était la plus jeune de cinq sœurs, avec deux ans d'écart avec moi, et nous étions les meilleurs amis du monde tout au long de notre vie. Sa mort a été extrêmement difficile pour moi, et je me suis engagé à devenir moine au Wat Langka (pagode) après sa mort.

Après son décès, les moines m'ont encouragé à méditer en marchant autour de la pagode. Je me suis promené autour de Preah Vihear du Wat Langka et j'ai remarqué par hasard une lumière provenant de la lampe de la statue de Bouddha. J'ai réussi à convaincre les moines de déplacer la statue pour voir d'où venait la lumière. Il a fallu 15 personnes pour déplacer le Bouddha en ciment et ils ont découvert une grotte cachée qui était fermée derrière une grande porte. Le portail semblait très sombre et effrayant, mais nous avons décidé de l'ouvrir pour découvrir ce qu'il y avait derrière. Lorsque nous l'avons ouverte, nous avons trouvé des piles et des piles d'urnes couvertes de toiles d'araignée et de poussière.




### BIBLIOTHÈQUE DES URNES DU WAT LANGKA

Wat Langka m'a autorisé à sortir les urnes pour les cataloguer et les photographier et nous avons identifié 464 urnes. Comme Wat Langka n'a pas encore retrouvé les restes du Vénérable Preah Nhanapavaravichea Louis Em (Vajirappanno), on pense que ses restes pourraient se trouver parmi ces centaines d'urnes. Le Vénérable Preah Nhanapavaravichea Louis Em (Vajirappanno) a été le premier chef de la pagode en 1912, et on lui attribue l'honneur extraordinaire d'avoir achevé la construction de cette pagode sacrée.

La plupart des urnes étaient tellement dégradées qu'il était impossible d'identifier l'écriture qu'elles portaient, et encore moins de déterminer leur âge. Certaines urnes sont datées, et nous pouvons dire qu'elles ont été laissées pendant la guerre civile au Cambodge dans les années 1980, et quelques-unes au début des années 1990. Cependant, nous avons appris, et



Team: Seang Chenda, Sorn Leak, Som Tola, Sok Vannak, Ly David, Chheng Veng, Long Aun, Som Bunthorn, Sreang Lyhour, Morm Sophat, Yin Nean and Teav Samphors

c'est notre conviction que beaucoup de ces urnes ont été abandonnées lors de l'évacuation de Phnom Penh en 1975.

Peu après l'entrée des Khmers rouges dans Phnom Penh en avril 1975, ils ont forcé toute la population à quitter la ville pour vivre et travailler dans des coopératives. Les gens ont été obligés à quitter la capitale avec seulement les objets qu'ils pouvaient transporter, et certaines personnes ont apporté les restes de leur famille au Wat Langka pour les mettre en sécurité — probablement dans l'espoir de pouvoir réclamer les urnes à leur retour à Phnom Penh.

## BIBLIOTHÈQUE DES URNES DU WAT LANGKA

Le moine qui a accepté ces urnes dans les années 1970 est décédé depuis et, apparemment, la connaissance de cette grotte cachée a disparu avec lui, car personne au Wat Langka n'était au courant de cette grotte secrète jusqu'à ce qu'elle soit redécouverte en 2015.

Avec l'aide généreuse de l'ambassade des États-Unis, de l'Agence américaine pour le développement international et des Seabees de la marine américaine au Japon, nous avons fait construire dix armoires en bois pour les urnes, qui sont aujourd'hui conservées dans ces armoires au Wat Langka.

Depuis que nous avons découvert les urnes et que nous les avons placées dans un endroit plus respectueux au Wat Langka, nous avons fait des annonces sur l'existence de ces urnes dans l'espoir que des familles se manifestent pour les réclamer. Selon la tradition bouddhiste, ces urnes ne peuvent être abandonnées et doivent être traitées avec respect. Cependant, près de huit ans se sont écoulés depuis la découverte de ces urnes et seules neuf familles se sont manifestées pour les réclamer. Nous pensons qu'au moins pour les urnes laissées lors de l'évacuation de Phnom Penh, il n'y a pas de membres de la famille en vie qui étaient présents lors de l'évacuation de 1975 pour réclamer ces urnes.





Seang Chenda & Sreang Lyhour



Après avoir discuté avec le chef du Wat Langka (pagode), Samdech Preah Thammalikhet Dr Sao Chanthol, et son comité de pagode, ils ont décidé de dédier un ensemble de pièces du Wat Langka non seulement pour conserver ces urnes, mais aussi pour servir de bibliothèque et d'endroit où les visiteurs peuvent apprendre, méditer et réfléchir sur l'histoire, la culture et la signification spirituelle des urnes dans le contexte de l'identité du Cambodge, de la tradition bouddhiste et de l'humanité en général.

Le Wat Langka a même réservé deux petites chambres pour que les visiteurs puissent y passer la nuit, ainsi qu'une autre salle pour la prière. C'est l'histoire de la «bibliothèque des urnes» du Wat Langka, qui abrite ces urnes, un livre d'histoire sur la bibliothèque et d'autres textes historiques et religieux.

À bien des égards, la préservation et la protection de ces urnes s'inscrivent dans le prolongement de la vision de Raphael Lemkin qui, depuis 1944, vise à prévenir et à punir le crime de génocide. Avant d'en arriver à la définition juridique actuelle du crime de génocide, Lemkin a identifié la destruction d'artefacts et de patrimoine culturels comme une sorte de génocide culturel. La récupération, de respect et de protection de ces urnes, qui ont failli être perdues par le régime des Khmers rouges il y a près de 50 ans lors de l'évacuation de Phnom Penh, est un travail qui s'inscrit dans la lutte permanente pour répondre au génocide culturel du passé, qui continue d'affliger le Cambodge et l'humanité aujourd'hui.

— *Cambodgemag* | *Presse magazine francophone*






PHOTOGRAPHERS: OUCH MAKARA, YOUK CHHANG, SEANG CHENDA,
LY DAVID, ENG SOKMENG AND YANN NIKOLA